អន្តរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ អត្ថន័យធម៌សាមគ្គី

www.hoksavann,com

ថ្ងៃទី១២ ធ្នូ ២០១០



សាមគ្គីប្រែថា ការព្រមព្រៀងគ្នា ការស្រុះស្រួលគ្នា ការមូលមតិគ្នា ការសុខចិត្តរៀងខ្លួនដោយពុំប្រឆាំងគ្នា ។ ព្រះពុទ្ធបរមគ្រូ ពេលដែលភិក្ខុសង្ឃទៅថ្វាយបង្គំ ព្រះអង្គមានព្រះពុទ្ធដីកាសំណេះសំណាលមានលក្ខណៈសួរសុខទុក្ខថា សវីរយន្តំ យាបនីយំ ខមនីយំ ប្រែថា សវីរយន្តរបស់អ្នករាល់គ្នា ប្រព្រឹត្តទៅយ៉ាងណា អត់ធន់បានឬទេ ? មួយទៀត ព្រះអង្គពុំភ្លេចទេតែងសួរថា តើព្រះសង្ឃមានការសាមគ្គីគ្នាឬទេ ? ត្រង់សំនួរនេះបញ្ជាក់ថា ព្រះអង្គបានយល់យ៉ាងច្បាស់ណាស់ថា ព្រះសង្ឃដែលនៅរស់ជាមួយគ្នា បើពុំមានសាមគ្គីគ្នាទេ ពុំបានសេចក្តីសុខឡើយ ។

ចំពោះសហគមន៍ព្រះសង្ឃផ្នែកពុទ្ធចក្រនេះ បើមានហេតុការណ៍ណាកើតឡើង ទាក់ទងនឹងការរស់នៅរបស់ព្រះសង្ឃ ព្រះពុទ្ធជាម្ចាស់តែងតែបញ្ញត្តិវិន័យ ។ ក្នុងព្រះវិន័យដែលព្រះអង្គបញ្ញត្តិនោះ មានទាំងខហាមឃាត់មិនឲ្យធ្វើ និងខអនុញ្ញត្តិឲ្យធ្វើ ក្នុងព្រះបំណងឲ្យភិក្ខុសង្ឃតាំងនៅក្នុងសេចក្តីបរិសុទ្ធ ដែលជាមូលដ្ឋាននាំឲ្យព្រះសង្ឃសាមគ្គីគ្នា បំពេញកិច្ចការរបស់ព្រះសង្ឃក្នុងអារាមនីមួយៗ ។ អ្នកដែលចូលមកបួស ទោះបីមានឋានៈខ្ពស់ទាបជាងគ្នាយ៉ាងណាក៏ដោយ ត្រូវតែស្ថិតនៅក្រោមធម៌វិន័យដែលព្រះពុទ្ធសំដែង ។ បន្ទាប់ពីព្រះសង្ឃមានចំនួនច្រើនហើយ ព្រះអង្គប្រគល់សិទ្ធិឲ្យព្រះសង្ឃសំរេចកិច្ចការរបស់ព្រះសង្ឃតាមការស្រុះស្រួលគ្នារបស់ព្រះសង្ឃ ដែលហៅថាសង្ឃកម្ម តាមវត្តអារាមរៀងខ្លួន ។ បើព្រះសង្ឃមានសាមគ្គីធម៌ហើយ សេចក្តីសុខចំរើនរមែងកើតមានក្នុងសហគមន៍ព្រះសង្ឃ ។

ចំពោះសង្គមផ្នែកអាណាចក្រវិញ បើសមាជិករបស់សង្គម ទាំងប្រជាពលរដ្ឋ ទាំងរដ្ឋអំណាច ធ្វើការងារគោរពតាមមុខងារនាទីរបស់ខ្លួន តាមច្បាប់របស់រដ្ឋនិងច្បាប់អង្គការសហប្រជាជាតិ មិនរំលោភសិទ្ធិមនុស្ស ពេលនោះសាមគ្គីភាពកើតមានហើយ ។ ប្រទេសណាមួយ ទោះមានទំហំតូច បើប្រជាពលរដ្ឋនិងអ្នកកាន់អំណាចរបស់ខ្លួនសាមគ្គីគ្នា មានឯកភាពជាតិហើយ បរទេសទោះបីមានកម្លាំងមានឥទ្ធិពលខ្លាំងយ៉ាងណាក៏ដោយ ក៏ពុំអាចចូលមកឈ្លានពានប្រទេសគេបានឡើយ ។ បរ-ទេសចូលមកឈ្លានពានបាន ភាគច្រើនដោយសារតែផ្ទៃក្នុងបែកបាក់សាមគ្គីគ្នា ។ យ៉ាងណាមិញ ព្រះរាជាណាចក្រកម្ពុជាកាលសម័យមហានគរមានទឹកដីធំទូលំទូលាយ មានអរិយធម៌ដ៏ខ្ពង់ខ្ពស់រុងរឿង ហើយបានជះឥទ្ធិពលរបស់ខ្លួនទៅលើប្រទេសជិតខាងទៀតផង ដោយសារពេលនោះខ្មែរសាមគ្គីគ្នាយ៉ាងរឹងមាំ ដោយត្រិបត្តិតាមធម៌ព្រហ្មវិហារ មានមេត្តាករុណាជាដើម ពុំបៀតបៀនគ្នា ។ សម័យក្រោយមក ខ្មែរបែកបាក់សាមគ្គីគ្នា មានជម្លោះផ្ទៃក្នុង ជាឱកាសល្អរបស់ប្រទេសជិតខាងបានចូលមកឈ្លានពានព្រះរាជាណាចក្រកម្ពុជា រំលោភយកទឹកដីកម្ពុជា ដែលកាលពីដើមមានទំហំធំ ឥឡូវនេះនៅទំហំតូចដូចសព្វថ្ងៃ ។ ដីដែលនៅសេសសល់តិចតួចនេះសោត ប្រទេសជិតខាងទាំងពីរក៏នៅតែព្យាយាមរំលោភយកជាបន្តទៅទៀត ជាពិសេសប្រទេសនៅទិសខាងកើត កំពុងរំលោភយកដោយស្របច្បាប់ តាមផែនការបោះបង្គោលព្រំដែន តាមសន្ធិសញ្ញា និងផែនទីមិនស្របច្បាប់អំឡុងឆ្នាំ១៩៨០ ធ្វើឲ្យស្របច្បាប់ឆ្នាំ២០០៥ ។ ខ្មែរណាការពារទឹកដីរបស់ខ្លួន ហ៊ាននិយាយថាការបោះបង្គោលនោះពុំត្រឹមត្រូវ ខ្មែរនោះនឹងប្រឈមមុខឡើងតុលាការកាត់ទោសជាប់គុក និងបង់ផាកពិន័យដូចមានកន្លងមកហើយ ។ ផែនការស្របច្បាប់ថ្មីមួយទៀតនៃប្រទេសទិសខាងកើត គឺដីសម្បទានជិតកន្លះលានហិកតានៅខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ និងកំពង់ធំនៃប្រទេសកម្ពុជាចំនួន៩៩ឆ្នាំ ដើម្បីដាំកៅស៊ូ ។ ប្រជាជនគេអាចមករស់នៅលើដីសម្បទានស្របច្បាប់ ក្នុងផ្លាកធ្វើជាកម្មករ ។ ប្រជាជនគេមានចំនួនជាង៨០លាននាក់ ចំណែកខ្មែរមានតែ១៤លាននាក់ តើអនាគត៩៩ឆ្នាំប្រជាជនគេនៅលើទឹកដីសម្បទានបង្កើតកូនចៅកើនចំនួនប៉ុន្មាននាក់ទៀត បើកើនលើស១៤លាននាក់ នោះខ្មែរនឹងទៅជាជនជាតិភាគតិចនៅលើដីកំណើតរបស់ខ្លួន ។

ចំពោះអត្ថន័យធម៌សាមគ្គីនេះ គឺសាមគ្គីបំពេញសេចក្តីល្អ ធ្វើឲ្យចំរើនសីលធម៌ និងចំរើនផលផានចិញ្ចឹមជីវិតគ្រួសារ និងជីវិតប្រទេសរបស់ខ្លួន ។ សាមគ្គីគ្នារក្សាអត្តសញ្ញាណជាតិ រក្សាទឹកដី រក្សាឯករាជ្យ រក្សាអធិបតេយ្យជាតិ រក្សាបូរណភាពទឹកដី រក្សាវប្បធម៌ដ៏ល្អផូរផង់របស់ខ្មែរ គឺព្រះពុទ្ធសាសនា ។ ពុំមែនសាមគ្គីគ្នាប្រើអំពើហឹង្សា កាប់សម្លាប់ លួចប្លន់ រំលោភលើកូនប្រពន្ធរបស់អ្នកដទៃជាដើមឡើយ ។ បើអ្នករាជការវិញ ពុំមែនសាមគ្គីគ្នាប្រព្រឹត្តអំពើពុករលួយ រំលោភសិទ្ធិមនុស្ស ជិះជាន់ប្រជាពលរដ្ឋរបស់ខ្លួន រំលោភយកដីរបស់ប្រជាពលរដ្ឋជាដើមឡើយ ។៚

☆ ☆

☆